# ការសម្ភាសន៍របស់អ៊ុំស្រី យីម លឿន

កៈ អ្នកសម្ភាសន៍គេ រត្ន ពិសី ខៈ អ្នកដែរត្រូវគេបានសម្ភាសន៍មាន យីម លឿន

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរអ៊ុំស្រីហើយនិងបងស្រីខ្ញុំបាទឈ្មោះ រត្ន ពិសី សូមអនុញ្ញាតធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់អ៊ុំស្រីហើយខ្ញុំបានធ្វើឡើងដោយសាកលវិទ្យាល័យមួយដែរមានឈ្មោះថា “ ប៊ី វ៉ាយ យូរ “ ដែលមានទីតាំងនៅសហរដ្ឋអាមេរិចណាអ៊ុំស្រីហើយខ្ញុំធ្វើការសម្ភាសន៍នេះដើម្បីទុកឲ្យកូនចៅជំនាន់ក្រោយរបស់អ៊ុំឲ្យគាត់បានស្តាប់ថាអ្នកជំនាន់មុនមានការលំបាកអ្វីខ្លះនៅក្នុងជីវិតរបស់អ្នកជំនាន់មុនថាពូកគេមានការជួបឧបសគ្គអ្វីខ្លះនៅក្នុងជីវិតប្រចាំថ្ងៃហើយមានការជួបបញ្ហាអ្វីខ្លះទៅអញ្ចឹងណាអ៊ុំ។ហើយខ្ញុំធ្វើនៅថ្ងៃទី ១០ ខែ ០៥ ឆ្នាំ ២០១៨ ណាអ៊ុំ។

ខៈ ចាំ!

កៈ អញ្ចឹងអ៊ុំសូមអធ្យាស្រ័យនៅនិងគេហៅភូមិអ្វីដែរហើយសង្កាត់អ្វីដែរអ៊ុំ?

ខៈ នៅនិងគេហៅភូមិបឹងសាឡាង សង្កាត់ ឬស្សីកែវ ភ្នំពេញ ។

កៈ អញ្ចឹងអ៊ុំមានឈ្មោះអ្វីដែរអ៊ុំស្រី?

ខៈ ខ្ញុំមានឈ្មោះថា យីម លឿន។

កៈ បាទ!អ៊ុំមានឈ្មោះថា យីន លឿនចឹងអ៊ុំមានឈ្មោះគេហៅខាងក្រៅទេ?

ខៈ ខាងក្រៅគេហៅថាខ្ញុំលឿនៗនឹង។

កៈ ចឹងអ៊ុំបើលឈ្មោះកាលនៅពីក្មេងវិញអ៊ុំតើគេហៅឈ្មោះនឹងដែលអ៊ុំ?

ខៈ ចាំ!គេហៅឈ្មោះនឹងដែរនឹង។

កៈ បាទ! មានឈ្មោះរឿនអ៊ុំ។

ខៈ អត់ទេមានឈ្មោះលឿនមិនមែនឈ្មោះ រឿនទេ។

កៈ បាទ! អញ្ចឹងដូចជាឈ្មោះពីក្មេងមក។

ខៈ មានឈ្មោះនិងម៉ងនិង។

កៈ អញ្ចឹងអ៊ុំសព្វថ្ងៃនិងអ៊ុំមានប្រជន្មាប៉ុន្មានហើយអ៊ុំ?

ខៈ អាយុ៨៨ឆ្នាំ។

កៈ អាយុ៨៨ឆ្នាំអ៊ុំ។

ខៈ ចាំ!

កៈ អញ្ចឹងអ៊ុំមាននៅចាំថាអ៊ុំកើតនៅថ្ងៃ ខែ ឆ្នាំណាដែរអ៊ុំ?

ខៈ អូរ អត់ចាំទេ!

កៈ អញ្ចឹងអ៊ុំមាននៅចាំឆ្នាំខ្មែរយើងមានឆ្នាំអីដែរអ៊ុំ?

ខៈ បើឆ្នាំខ្មែរយើងមានឆ្នាំ រក ។

កៈ ឆ្នាំ រក អ៊ុំ។

ខៈ ចាំ!

កៈ អញ្ចឹងអ៊ុំមាននៅចាំទីកន្លែងកំណើតរបស់អ៊ុំទេអ៊ុំ?

ខៈ អត់អាលឹង។

កៈ ដូចជាអ៊ុំកើតនៅស្រុកណាខេត្តណាអញ្ចឹងណា។

ខៈ អត់ចាំទេ។

កៈ ហើយស្រុកកំណើតអ៊ុំនៅតូចមកអ៊ុំមានចាំទេ?

ខៈ អរ អត់ចាំទេពេលនិងខ្ញុំនៅតូចពេកតែខ្ញុំមកនៅភ្នំពេញយូរហើយ។

កៈ បាទ! អញ្ចឹងអ៊ុំមាននៅចាំថាអ៊ុំមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ មានតាបងប្អូនបង្កើតខ្ញុំនិងហើយខ្ញុំមានបងប្អូនពីរនាក់ទេ។

កៈ អញ្ចឹងអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំពៅគេ។

កៈ អត់អ៊ុំពៅគេអ៊ុំ។

ខ៖ ចា៎!

ក៖ ហើយបងៗរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ បងខ្ញុំឈ្មោះយាយលឹង។

ក៖ បាទ! ឈ្មោះយាយលឹងគាត់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ គាត់និងបងគេបង្អស់។

ក៖ ហើយទីពីរអ៊ុំ?

ខ៖ ហើយបងខ្ញុំឈ្មោះបងរ៉ូលតែងាប់បាត់ហើយ។

ក៖ មូលហេតុអីបានគាត់ស្លាប់អ៊ុំ?

ខ៖
គាត់ចេញមកពីជំនាន់អាពតណាស់ដល់ពេលគេជីកដីអង្គុងហើយគេយកគាត់ទៅវាយចោលទៅ។

ក៖ បាទ!

ខ៖ ដល់ពេលគេវាយចោលទៅដល់ពេលយួនចូលមកទៅគេក៏អត់វាយយើងវិញទៅ។

ក៖ បាទ!

ខ៖ ដល់និងវាដាក់ចូលអង្គុងហើយនិងពេលដល់វាឃើញទៅវាលែងវាយទៅ។

ក៖ បាទ! អញ្ចឹងបានរួចផុតទៅ។

ខ៖ ចា៎!

ក៖ អញ្ចឹងដោយសារពេលគេមករំដោះអញ្ចឹងគាត់អត់បានស្លាប់នៅជំនាន់អាពតទេ។

ខ៖ ចា៎! គាត់អត់បានស្លាប់នៅជំនាន់អាពត់ទេ។

ក៖ បាទ! ពេលនិងបានចេញពីអាពតហើយបានគាត់មានជម្ងឺឈឺចាស់ស្លាប់ចឹងអ៊ុំណាស់?

ខ៖ អត់ទេដូចថាគាត់លក់អីៗចឹងណាស់កាត់ក៏ខ្យលករ។

ក៖ បាទ!ដោយសារសុខភាពគាត់ខ្សាយចឹងអ៊ុំ?

ខ៖
ចា៎!គាត់ខ្យលករគាត់មិនបានស្លាប់កាលជំនាន់អាពតទេគាត់បានស្លាប់ជំនាន់ឥឡូវៗនឹងទេ។

ក៖
បាទ!ចឹងកាលនៅពីក្មេងវិញណាស់អ៊ុំតើអ៊ុំចូលចិត្តធ្វើអ្វីខ្លះជាមួយពួកគាត់ណាស់ដូចថាមានអនុស្សាវរីយអ្វីខ្លះចឹងណាស់អ៊ុំ?

ខ៖ អត់ទេអត់មានតែម្តង។

ក៖ បាទ!ដូចជាដើរចាប់ក្តាមខ្យងជាមួយគ្នាអីចឹងណាអ៊ុំ?

ខ៖ គ្មានទេខ្ញុំគ្មានតែម្តង។

ក៖ ហើយចុះជាមួយបងប្អូនអីមានទេអ៊ុំ?

ខ៖ អត់ដែលយើងបែកគ្នាតាំងពីតូចមកម្លេះ។

ក៖ អរអ៊ុំបែកគ្នាតាំងពីពេលណាមកជាមួយបងប្អូនអ៊ុំដែរ?

ខ៖
បែកយូរហើយបែកតែឥឡូវអាបងខ្ញុំនឹងស្រីនឹងនៅនឹងតាបងប្រុសខ្ញុំបានបែកពីជំនាន់អាពតនឹង។

ក៖ បែករកគ្នាអត់ឃើញម៉ងឬមួយក៏បែកមិចដែលអ៊ុំ?

ខ៖ បែករកឃើញហើយតែនៅម្តុំកំពង់លួង។

ក៖ បាទ!

ខ៖
តែឥឡូវគាត់ស្លាប់បាត់ហើយមិនមែនគាត់ស្លាប់ជំនាន់អាពតយ់ទេគាត់ស្លាប់នៅជំនាន់យើងនេះ។

ក៖
បាទ!ចឹងតើសព្វថ្ងៃនឹងតើគាត់មានរស់នៅណាខ្លះទេដែលបងប្អូនអ៊ុំដែលនៅរស់ណាស់អ៊ុំ?

ខ៖ បងខ្ញុំគាត់រស់នៅកំពង់អំពិលមួយ។

ក៖ បាទ!កំពង់អំពិលនឹងនៅណាវិញអ៊ុំ?

ខ៖ នៅវិហារសួគ៌នឹង។

ក៖ បាទ!វិហារសួគ៌ ខេត្ត កណ្តាល យើងនឹងអុំ?

ខ៖ មានទេបងប្អូនមករាល់ទៃដងនឹង។

ក៖ បាទ!ចឹងបងប្អូនអុំរាល់ថ្ងៃនឹងនៅសល់២នាក់អុំ?

ខ៖ ចាំ!នៅសល់តែ២នាក់។

ក៖ បាទ!ពីនាក់នឹងប្រុសមួយស្រីមួយអុំ?

ខ៖ អត់ទេស្រីទាំងពីនាក់នឹង។

ក៖ បាទ!ចឹងអុំមករស់នៅនឹងតើគេហៅភូមិនឹងថាភូមិអីគេដែលអុំ?

ខ៖ គេហៅថាភូមិ បឹងសាឡាង។

ក៖ បាទ!ភូមិនឹងគេហៅថាភូមិបឹងសាឡាងចឹងអុំអាចប្រាប់ខ្ញុំបានទេថាសង្កាត់អីដែលអុំ?

ខ៖ សង្កាត់ បឹងសាលាងនឹងម៉ង។

ក៖ អរចង់និយាយថា ភូមិបឹងសាលាង សង្កាត់ បឹងសាលាងតែម្តងហើយខណ្ឌន
រាជធានីភ្នំពេញនឹងទៅ?

ខ៖ ចាំ!

ក៖ បាទ!ចឹងតើឈ្មោះម៉ាក់ប៉ារបស់អុំតើមានឈ្មោះអ្វីដែលអុំ?

ខ៖ ប៉ាខ្ញុំគាត់មានឈ្មោះថា យិម ។

ក៖ បាទ!ហើយចុះឈ្មោះម៉ាក់វិញអុំតើឈ្មោះអីដែលអុំ?

ខ៖ ខ្ញុំភ្លេចហើយខ្ញុំអត់ចាំសោះ។

ក៖ បាទ!ចឹងជាមូលហេតុអ្វីបានជាមីងអត់ចាំឈ្មោះម្តាយ?

ខ៖ អរម៉ាក់ខ្ញុំឈ្មោះយាយ ព្រិន ។

ក៖ បាទ!ចឹងបានខ្ញុំថាជាមូលហេតុអ្វីបានអុំអត់បានស្គាល់ឈ្មោះម៉ាក់អុំចឹងណាស់?

ខ៖ ឪឈ្មោះ ពុក ម៉ែឈ្មោះ ព្រិន ។

កៈ បាទ!ចឹងឥឡូវគាត់នៅណាដែលអ៊ុំ?

ខៈ គាត់ស្លាប់បាត់ហើយនឹង។

កៈ
បាទ!ចឹងនៅពេលដែលគាត់បានស្លាប់នឹងនៅឆ្នាំណាដែលអ៊ុំលោកឪពុករបស់អ៊ុំស្លាប់នៅឆ្នាំណាម្ដាយរបស់អ៊ុំស្លាប់នៅឆ្នាំណាអីចឹងណាស់អ៊ុំតើអ៊ុំមានបានចាំទេ?

ខៈ ពេលនឹងខ្ញុំនៅតូចនឹងបើម្ដាយខ្ញុំគាត់ស្លាប់នៅអាយុ៦៧ឆ្នាំ។

កៈ បាទ!ចឹងអ៊ុំមានចាំថាគាត់កើតនៅឆ្នាំណាខែណាអីដែលអ៊ុំតើអ៊ុំមានចាំទេ?

ខៈ ខ្ញុំអត់ចាំទេ។

កៈ បាទ!ចឹងចុះឆ្នាំខ្មែរដូចជា ជូត ឆ្លូវ ខាល ថោះ អីអ៊ុំ?

ខៈ អត់ទាំងអស់ខ្ញុំអត់ចាំសោះ។

កៈ ហើយចុះឪពុកម្ដាយរបស់អ៊ុំតើគាត់ជាអ្នករស់នៅខេត្តណាដែលអ៊ុំ?

ខៈ គាត់ជាអ្នកស្អាងព្រៃតូច។

កៈ បាទ! ស្អាងព្រៃតូចនិង។

ខៈ ចាំ! អ្នកស្អាងព្រៃតូចនិងហើយ។

កៈ ហើយអញ្ចឹងគាត់រស់និងទាំងពីរនាក់តែម្ដងអ៊ុំ។

ខៈ ឪពុករបស់ខ្ញុំគាត់នៅស្វាងឯណុស។

កៈ បាទ!
អញ្ចឹងឪពុកម្ដាយរបស់អ៊ុំគាត់រស់នៅស្រុកផ្សេងគ្នាហើយរស់នៅខេត្តជាមួយគ្នាមែនអ៊ុំស្រី?

ខៈ ចាំ! ពួកគាត់នៅខេត្តកណ្ដាលនិងហើយ។

កៈ បាទ! អញ្ចឹងម្ដាយរបស់អ៊ុំរស់នៅស្រុកផ្សេងគ្នាហើយអ្នកនៅខេត្តជាមួយគ្នា។

ខៈ ចាំ!

កៈ បាទ! ហើយអញ្ចឹងដូចជាពួកគាត់ជាខេត្តជាមួយគ្នាហើយភូមិខុសគ្នាអញ្ចឹងអ៊ុំ។

ខ៖ ចាំ!

ក៖ អញ្ចឹងសម្រាប់ឪពុកម្តាយរបស់អ៊ុំវិញតើគាត់ប្រកបរបរអ្វីដើម្បីចិញ្ចឹមអ៊ុំស្រី?

ខ៖ គាត់ធ្វើការកម្មករគេហើយម្តាយរបស់ខ្ញុំគាត់ធ្វើកម្មករគេដែរនិង។

ក៖ អញ្ចឹងគាត់ធ្វើនៅភ្នំពេញនិងតាអ៊ុំ។

ខ៖ ចាំ! គាត់ធ្វើការនៅនិងតា។

ក៖ បាទ!

ខ៖ ចាំ! គាត់ធ្វើការនៅភ្នំពេញនិង។

ក៖ បាទ! ហើយអញ្ចឹងពេលនិងអ៊ុំមានចាំថាគាត់មានធ្វើការអីផ្សេងទៀតទេអ៊ុំ។

ខ៖ ខ្ញុំអត់សូវដឹងទេពេលនិងខ្ញុំនៅតូចណាហើយតូចនៅឡើត។

ក៖ បាទ! ហើយអញ្ចឹងអ៊ុំមានដឹងថាធ្វើអីផ្សេងទៀតទេ?

ខ៖ អត់ដឹងទេថាគាត់ធ្វើអីទេ។

ក៖ ហើយអញ្ចឹងដឹងថាឪពុកអ៊ុំប្រកបមុនរបស់អីដែរ?

ខ៖ ឪពុករបស់ខ្ញុំគាត់ធ្វើទាហាន។

ក៖ បាទ! អញ្ចឹងតើគាត់ធ្វើទាហានអីគេដែរអ៊ុំស្រី។

ខ៖ ខ្ញុំអត់ដឹងថាគាត់ធ្វើទាហានអីទេ។

ក៖ ដូចជាទាហានខ្មែរក្រហមឬក៏ទាហានលន់នល់អ៊ុំស្រី។

ខ៖ គាត់ធ្វើទាហានអីប្រហែលទាហានខ្ញុំអត់សូវចាំទេ។

ក៖ បាទ! ពេលនិងគាត់ស្មាគចិត្តចូលធ្វើទាហានឬក៏គេចាប់គាត់ធ្វើទាហានអ៊ុំ។

ខ៖ ចាំ !ពេលនិងគេចាប់គាត់ចូលធ្វើទាហានតែម្តងនិងណា។

ក៖ បាទ! អញ្ចឹងពេលនិងគេចាប់គាត់ចូលធ្វើទាហានម៉ងអ៊ុំស្រី?

ខ៖ អត់ទេដូចជាគាត់ស្មាគចិត្តចូលបម្រើលកងទ័ពម៉ងនិងណា។

កៈ បាទ! គាត់សុខចិត្តធ្វើការខាងទាហាននិង?

ខៈនិងហើយ។

កៈឪពុករបស់អ៊ុំគាត់ទៅធ្វើការនិងខាងអីទាហាននិងផ្នែកអីគេដែលអ៊ុំពេលនិង?

ខៈគាត់បានធ្វើជាទាហានជើងក្របាមនិងកាលនិង។

កៈកាលនិងគាត់បានធ្វើជាទាហានជួលមុនឬក៏ទាហានអីគេដែលអ៊ុំ?

ខៈខ្ញុំមិនបានដឹងទេការនិងខ្ញុំនិង។

កៈជាទាហានការពារភូមិឬក៏ជាទាហានអីគេដែលអ៊ុំ?

ខៈជំនាន់និងខ្ញុំមិនបានដឹងថាគាត់ជាទាហានអីគេដែលទេកាលនិង៕

កៈអូបាទអ៊ុំ?

ខៈទាហាននិងអត់បានទេអាពតអីនិង។

កៈចឹងកាលនិងគាត់ជាទាហានជំនាន់អាពតអីដែលកាលនិងអ៊ុំ?

ខៈគាត់ជាទាហានជំនាន់អីស្លេះនិងតែជំនាន់អាពតនិងបើវាដឹងថាយើងជាទាហានជំនាន់និងវាយកយើងទៅសំលាប់ចោលហើយកាលនិង។

កៈ
ហើយកាលនិងគេមិនបានអោយលឺឈ្មោះអត់បានទេកាលនិងតែអោយដឹងនិងគេស្អាត់តែម្តងនិងកាលនិងពិបាកណាស់។

ខៈ គាត់ចេញតែពីនិងទៅគាត់គ្មានអីទេគាត់ចេញពីនិងគាត់ទៅនៅស្រុកភូមិគាត់និង។

កៈ បាទ!
បើនិយាយពីលក្ខណៈរបស់គាត់តើអ៊ុំគិតថាគាត់ជាមនុស្សបែបណាដែរអ៊ុំស្រីឬគាត់ជាមនុស្សស្លូតបូត?

ខៈ គាត់និងជាមនុស្សស្លូតបូតណាស់។

កៈ
បាទ!អញ្ចឹងគាត់ដែលកាចដាក់អ៊ុំស្រីទេអ៊ុំហើយគាត់ធ្វើទាហានអញ្ចឹងប្រហែលគាត់កាចហើយអញ្ចឹង

គាត់មិតចិតទេអ៊ុំស្រី?

ខ៖ ចា៎!
គាត់ស្លូតហើយលឺតែម៉ែខ្ញុំគាត់និយាយប្រាប់ខ្ញុំទេហើយខ្ញុំអត់សូវដឹងរឿងអីពីគាត់ដែរ។

ក៖ បាទ!
អញ្ចឹងអ៊ុំស្រីមាននៅចាំថាជីដូនជីតារបស់លោកឪពុករបស់អ៊ុំហើយអ្នកម្ដាយរបស់អ៊ុំមាន
នៅទេអ៊ុំថាគាត់មានឈ្មោះអីទៅអ៊ុំស្រី?

ខ៖ គាត់ឈ្មោះ យឹម។

ក៖ បាទ! យឹមនិងឈ្មោះយាយឬក៏ឈ្មោះតាអ៊ុំស្រី?

ខ៖ ឈ្មោះតា។

ក៖ បាទ! ហើយចុះខាងម្ដាយរបស់អ៊ុំមានបានស្គាល់ទេអ៊ុំស្រី?

ខ៖ ដូចខាងម្ដាយរបស់ខ្ញុំដូចអត់ស្គាល់ទេ។

ក៖ ហើយចុះឈ្មោះយាយមានឈ្មោះអីគេដែរអ៊ុំស្រី?

ខ៖ ឈ្មោះអត់ស្គាល់ទេ។

ក៖ អញ្ចឹងឈ្មោះយាយតារបស់អ៊ុំចាំដែលប៉ុន្មានទេអ៊ុំស្រី?

ខ៖ ចា៎! ខ្ញុំចាំដែលប៉ុន្មានទេហើយខ្ញុំចាំថាឈ្មោះ យឹមនិងទេ។

ក៖ បាទ! ហើយឈ្មោះ យឹមនិងខាងឪពុកឬក៏ខាងម្ដាយអ៊ុំស្រី?

ខ៖ ខាងម្ដាយទាំងអស់និងណា។

ក៖ បាទ! ខាងម្ដាយ។

ខ៖ ចា៎! ខាងម្ដាយទាំងអស់និងហើយបើម្ដាយគាត់អត់ស្គាល់ទេ។

ក៖ បាទ! អត់ស្គាល់។

ខ៖ ស្គាល់ឈ្មោះឪពុក។

ក៖ បាទ! ហើយអញ្ចឹងអ៊ុំចាំថាគាត់កើតនៅថ្ងៃណាខែណាឆ្នាំណាទេអ៊ុំស្រី?

ខ៖ អត់ចាំទេ។

ក៖ អញ្ចឹងគាត់អត់បានប្រាប់អ៊ុំទេអ៊ុំស្រី។

ខ៖ ចា៎! គាត់អត់មានបានប្រាប់ទេថាគាត់កើតនៅថ្ងៃណាទេ។

ក៖ បាទ! គាត់អត់ដែលប្រាប់ផងបាទចឹងលោកឪពុករបស់អ៊ុំមានបានដឹងអំពីសាច់រឿងរបស់គុងគាត់ពីមុនមកគាត់មានការលំបាកអ្វីខ្លះហើយម៉ាគាត់មានការលំបាកអ្វីខ្លះតើគាត់មានដែលបានប្រាប់អ៊ុំទេ?

ខ៖ អត់ទេគាត់មិនដែលប្រាប់ខ្ញុំផងនឹង។

ក៖ បាទ!គាត់អត់បានប្រាប់អ៊ុំទេចឹងអ៊ុំបានតែចាំឈ្មោះគាត់ទេ?

ខ៖ ចា៎!ចាំឈ្មោះតាមួយនឹង។

ក៖ បាទ!ចឹងតើគាត់ធ្វើការអ្វីដែលអ៊ុំ?

ខ៖ គាត់អត់មានធ្វើការអ្វីផងខ្ញុំអត់ដឹងអាលីងម៉ង។

ក៖ បាទ!ដោយសារការនឹងអ៊ុំនៅតូចពេក?

ខ៖ ចា៎!ខ្ញុំដឹងថាលោកឪពុកខ្ញុំគាត់ជាអ្នកធ្វើជាទាហានជើងក្រហមហើយនឹងម្ដាយខ្ញុំគាត់ជាអ្នកធ្វើការរោងចក្រខ្ញុំដឹងតាប៉ុននឹង។

ក៖ បាទ!ចឹងអ៊ុំតើក្រុមគ្រួសាររបស់អ៊ុំតើពួកគាត់ជាអ្នករស់នៅក្នុងខេត្តណាដែលអ៊ុំតាំងពីដើមមកណាស់អ៊ុំតើពួកគាត់ជាអ្នកនៅខេត្តណាដែលអ៊ុំ?

ខ៖ ពីដើមមកអ្នកនៅស្វាងព្រៃតូចនឹង។

ក៖ បាទ!ស្វាងព្រៃតូចខេត្តកណ្ដាលនឹងបាទចឹងអ៊ុំមករស់នៅភ្នំពេញនឹងតាម្នាក់ឯងទេ?

ខ៖ ចា៎!ខ្ញុំនៅពីរនាក់បងបញអូននឹង។

ក៖ បាទ!អ៊ុំរស់នៅនឹងតាពីនាក់បងប្អូនទេ?

ខ៖ កូនគេមានប្ដីទៅគេទៅនៅជាមួយកូនគេប្ដីគេទៅ។

កៈ បាទ!កូនអ៊ុំគេក៏ទៅនៅជាមួយប្ដីទៅ?

ខៈ ចាំ!នឹងហើយ។

កៈ បាទ!ចឹងអ៊ុំមានសាច់ដែលគាត់រស់នៅក្រៅប្រទេសណាអ៊ុំដូចជាប្រទេសថៃ វៀតណាមអីនឹងអ៊ុំតើមានទេអ៊ុំ?

ខៈ អត់មានទេ។

កៈ បាទ!ដូចជាជីដូនមួយជីតូចមួយអីអ៊ុំតើមានទេអ៊ុំ?

ខៈ អត់ទេអត់មានផងនឹង។

កៈ បាទ!ចឹងអ៊ុំតើស្វាមីរបស់អ៊ុំតើគាត់មានឈ្មោះអ្វីដែលអ៊ុំ?

ខៈ ខ្ញុំមិនចង់និយាយទេ។

កៈ បាទ!អត់អីទេអ៊ុំ?

ខៈ ទាន់ហាន់។

កៈ បាទ!ទាន់ហាន់អ៊ុំ?

ខៈ ដូចថាមិនចង់និយាយទេ។

កៈ
បាទ!គាត់អត់គិតគូររឿងគ្រួសារចឹងអ៊ុំមានចាំថាបើលឈ្មោះកូនបានប្រាប់ហើយចឹងតើអ៊ុំមានចាំថាអ៊ុំបានរៀបការជាមួយគាត់តាំងពីពេលណាដែលអ៊ុំ?

ខៈ មិនដឹងប៉ុន្មានទេខ្ញុំមិនដឹងផងនឹង។

កៈ បាទ!ចឹងតើកូនច្បងរបស់អ៊ុំតើគាត់មានអាយុប៉ុន្មានហើយសព្វថ្ងៃនឹងណាស់អ៊ុំ?

ខៈ កូនខ្ញុំមានអាយុជិត៤០ឆ្នាំហើយ។

កៈ បាទ!ជិត៤០ឆ្នាំហើយ?

ខៈ អរ៣៨ឆ្នាំ។

កៈ
បាទ!គាត់អាយុ៣៨ឆ្នាំហើយបាទចឹងមានន័យថាអ៊ុំបានរៀបការជាមួយស្វាមីរបស់អ៊ុំនឹងមុនអាពតទៀត?

ខៈ មុនអាពតណាទុបតែឥឡូវទេ។

កៈ បាទ!កូនអ៊ុំអាយុ៣៨ចឹងអ៊ុំរៀបការក្រោយអាពតទៀត?

ខៈ អត់ទេទុបតែឥឡូវនឹងទេ។

កៈ
បាទ!ចឹងនៅពេលអ៊ុំបានស្គាល់ស្វាមីរបស់អ៊ុំដំបូងនឹងតើអ៊ុំបានស្គាល់គាត់នៅកន្លែងណាដែលដូចជានៅកន្លែងធ្វើការនៅភូមិជិតគ្នាឬមួយក៏អ៊ុំបានស្គាល់គាត់នៅណាដែលអ៊ុំ?

ខៈ គាត់ធ្វើទាហាននៅនេះនៅទងហាលដែកនេះ។

កៈ បាទ!គាត់ធ្វើទាហាននៅនឹងទើបបានស្គាល់អ្នកមីងនៅនឹងទៅ?

ខៈ ចាំ!នៅហាលរតភ្លើងនឹង។

កៈ បាទ!ចឹងនៅពេលនឹងអ៊ុំធ្វើការអ្វីបានជាអ៊ុំបានស្គាល់គ្នាអ៊ុំ?

ខៈ ខ្ញុំពេលនឹងរកស៊ីចាក់នំគ្រួកនឹង។

កៈ បាទ!គាត់ទិញអីទៅគាត់ក៏ស្គាល់អ៊ុំទៅដូចថាលួតស្នេហ៍អ្នកលក់នំគ្រួក?

ខៈ
បេះស្លឹកអីហើយខ្ញុំវៀតតានៀលណាស់បេះស្លឹកបេះអីដើរបេះតាមពីមុនគេខ្ចបស្លឹកឈូកមិនដូចឥឡូវគេមានថងណា។

កៈ បាទ!ពីមិនកាត់ស្លឹកឈូកខ្ចបទៅ?

ខៈ ចាំ!

កៈ បាទ!ដល់ឥឡូវគេមានថងអីត្រឹមត្រូវទៅ?

ខៈ
ចាំ!មិនដូចពីមុនខ្ចបស្លឹងឈូកទេកាលពីជំនាន់នឹងខ្ញុំលក់កាផ្លាកយើងចិតវាទៅយើងមិនយកទៅហារដល់ពេលយើងហាររួតទៅយើងមិនចង់វាដុំៗដល់ពេលទៅយើងលក់ទៅមួយដុំ៥រយទៅយកទៅលក់នៅផ្សារកណ្តានឹងផ្សារចាស់ទៅពិននឹង។

កៈ បាទ!ចឹងមុខរបរដែលអ៊ុំប្រកបនឹងតើអ៊ុំប្រកបប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ តាំងពីខ្ញុំអាយុ១៥ឆ្នាំណាស់។

កៈ
បាទ!អ៊ុំប្រកបមុខរបរជាអ្នកលក់កាផ្លាកនឹងតាំពីអាយុ១៥ឆ្នាំហើយបាទចឹងនៅពេលនឹង
ណាស់អ៊ុំនៅពេលដែលអ៊ុំចេញលក់នឹងកាលនៅជំនាន់នឹងតើគេជិះកង់ឬម៉ូតូដែលអ៊ុំ?

ខៈ អត់ទេ។

កៈ ដើរទូលលក់ម៉ងអ៊ុំ?

ខៈ អត់ទេអង្គុយលក់នឹងដូចយើងលក់កាទាវនឹងយើងអង្គុយលក់ចឹងចាក់លក់។

កៈ បាទ!មិនអ៊ុំបានប្រាប់ខ្ញុំថាអ៊ុំទៅលក់នៅផ្សារ?

ខៈ
អត់ទេដូចអានោះលក់ស្លឹកឈូកផ្លែកាផ្លាកនឹងណាស់លក់នឹងនៅផ្សារកណ្តានឹងណាស់ពេ
លនឹងយើងដើរលក់នឹងដើរលក់ដល់ម៉ោង៤រហូតដល់ម៉ោង៥ ៦នឹង។

កៈ បាទ!៤យប់នឹងមែងអ៊ុំ?

ខៈ ចាំ!៥
៦ភ្លឺនឹងអត់មានអីជិះទេដើរទៅម៉ងយើងអត់មានលុយជិះល្មមយើងមកវិញយើងមានលុយ
ទិតទូតយកមកគ្រាន់បានចិញ្ចឹមគ្រួសារម្តាយអីចឹងទៅមានតាពីតនាក់ទេបងប្អូនណាស់។

កៈ
បាទ!ចឹងនៅពេលអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងតើអ៊ុំរៀបអាពាហ៍ពិពាហ៍នៅភ្នំពេញនឹងម៉ងឬមួ
យក៏នៅខេត្តកណ្តានឹងអ៊ុំ?

ខៈ ខ្ញុំរៀបអាពាហ៍ពិពាហ៍នឹងនៅនិង។

កៈ បាទ!ចឹងអ៊ុំមានចាំថាអ៊ុំរៀបអាពាហ៍ពិពាហ៍បានប៉ុន្មានឆ្នាំហើយ?

ខៈ
ហើយនិយាយមិនរួតទេតាំពីប្តីខ្ញុំមានស្រីមកខ្ញុំវង្វេងខ្ញុំផឹកស្រាពេកទៅខ្ញុំចង់វង្វេងវង់ង្វានអ
ស់ហើយឥឡូវ។

កៈ បាទ!អ៊ុំបានទទួលទាន់ស្រាពេកចឹងតើឥឡូវតើអ៊ុំឈប់នៅអ៊ុំ?

ខ៖ ខ្ញុំឈប់ហើយដល់ចៅខ្ញុំបួននាក់ហើយខ្ញុំចិញ្ចឹមរាល់ថ្ងៃនឹងនេះ។

ក៖ បាទ!ចឹងអ៊ុំកុំពិសាស្រានាំអោយខូតសុខភាពទេ?

ខ៖ ចាំ!ដូចថានៅពេលហូបស្រាអត់មានពីណាគេចិញ្ចឹមចៅ។

ក៖ បាទ!អញ្ចឹងអ៊ុំរាល់ថ្ងៃអ៊ុំប្រកបមុនរបរអីគេដែរអ៊ុំ?

ខ៖ ខ្ញុំធ្វើការលាងចាន់ឲ្យគេ។

ក៖ ហើយបានមួយថ្ងៃប៉ុន្មានដែរអ៊ុំស្រី?

ខ៖ មួយថ្ងៃបានមួយម៉ឺនទេ។

ក៖ បាទ!

ខ៖ បានមួយម៉ឺននិងចែកឲ្យចៅទៅរៀនអស់បាត់ហើយនិង។

ក៖ បាទ!
អញ្ចឹងបើនិយាយពីសាច់រឿងអាពាហ៍ពិពាហ៍របស់អ៊ុំជាមួយស្វាមីរបស់អ៊ុំតើមានភាពជូរចិតយ៉ាងមិចដែរអ៊ុំស្រី?

ខ៖ បើនិយាយទៅខ្ញុំពិបាកនិយាយណាស់។

ក៖ ហើយនេះជាកូនច្បងរបស់អ៊ុំស្រីមែនអ៊ុំ?

ខ៖ ចាំ! មិនមែនកូនច្បងរបស់ខ្ញុំទេកូនច្បងខ្ញុំគេទៅណាបាត់ទៅណា។

ក៖
អញ្ចឹងបងស្រីពេលរស់នៅជាមួយគាត់តើបងស្រីមានភាពជូរចិតជាមួយគាត់យ៉ាងមិចដែរបងស្រី?

ខ៖
ខ្ញុំដូចជាអត់មានភាពជូរចិតជាមួយអីផងនិងឪគាត់ក៏ចិញ្ចឹមហើយម៉ែគាត់ពិបាកតែខ្ញុំអត់ពិបាកអីទេខ្ញុំរាល់ថ្ងៃនិងនោះខ្ញុំមានតែពិបាកចិត្តជំនួសគាត់និង។

ក៖ អញ្ចឹងកាលពីមុនមកតើបងមានជីវភាពបែបណាខ្លះដែរ?

ខ៖ ចាំ! បើពីមុនមានជីវភាពលំបាកដែលនិង។

ក៖ បាទ! តើមានការលំបាកអ្វីខ្លះបងដូចអត់មានលុយកាកអីអញ្ចឹងបងស្រី?

ខ៖ ចាំ! រឿងនិងត្រូវហើយពេលខ្លះអត់មានលុយទិញម្ហូបផងពេលខ្លះនិង។

ក៖
អញ្ចឹងពេលដែលអ៊ុំស្រីបានចាប់ដៃជាមួយស្វាមីរបស់អ៊ុំស្រីនិងមានកូនប៉ុន្មាននាក់ដែរអ៊ុំស្រី
?

ខ៖ មានកូនចំនួនបួននាក់។

ក៖ បាទ! បានបួននាក់ហើយស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរអ៊ុំស្រី?

ខ៖ ចាំ!
បើខ្ញុំនិយាយតាមត្រង់និងខ្ញុំមានកូនស្រីបីនាក់ហើយមួយទៀតខ្ញុំខឹងប្តីខ្ញុំពេកខ្ញុំយកឲ្យគេ
ទៅ។

ក៖ ហើយឥឡូវគាត់មានអាយុប៉ុន្មានហើយអ៊ុំស្រី?

ខ៖ ខ្ញុំអត់ដឹងទេ។

ក៖ បាទ!

ខ៖ ខ្ញុំនិយាយតាមត្រង់និងកូនខ្ញុំមានស្រីបីនាក់ហើយកូនប្រុសពីរនាក់។

ក៖ បាទ! អញ្ចឹងអ៊ុំមានកូនប្រាំនាក់ប្រុសពីរហើយស្រីបីនាក់អ៊ុំស្រី?

ខ៖ ចាំ!

ក៖ ហើយអញ្ចឹងកូនទីមួយរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំស្រី?

ខ៖ កូនទីមួយមានឈ្មោះស្រីឡៃ។

ក៖ បាទ! ហើយកូនទីពីរមានឈ្មោះអីគេដែរអ៊ុំស្រី?

ខ៖ ទីពីរមីនាគ។

ក៖ ហើយអញ្ចឹងបងស្រីមានឈ្មោះអីគេដែរបងស្រី?

ខ៖ ខ្ញុំមានឈ្មោះ ហៀត។

ក៖ ហើយកូនទីបីមានឈ្មោះអីគេទៅអ៊ុំស្រី?

ខ៖ ទីបី ហ៊ាន។

កៈ ទីបី ហ៊ានអ៊ុំ។

ខៈ អឺ ។

កៈ ហើយកូនទីបួនអ៊ុំស្រី?

ខៈ កូនទីបួនមានឈ្មោះហុង។

កៈ ហើយអញ្ចឹងហុងនិងពៅគេអ៊ុំស្រី។

ខៈ ចាំ! ហុងនិងពៅគេនិងណា។

កៈ ហើយកូនយកគេមានឈ្មោះអីគេអ៊ុំស្រី?

ខៈ មួយនិងអត់ដឹងឈ្មោះអីទេអត់ទាន់ដាក់ឈ្មោះទេ។

កៈ បាទ! អញ្ចឹងអ៊ុំអត់ទាន់ដាក់ឈ្មោះទេ។

ខៈ ចាំ!

កៈ ហើយអញ្ចឹងអ៊ុំកើតមកភ្លាមអ៊ុំឲ្យគេភ្លាមអ៊ុំស្រី?

ខៈ ចាំ! កើតមកភ្លាមខ្ញុំឲ្យគេភ្លាមហើយខ្ញុំឲ្យបងប្អូននិង។

កៈ បាទ! អញ្ចឹងអ៊ុំឲ្យទៅបងប្អូនរបស់អ៊ុំស្រី។

ខៈ ចាំ! ហើយខ្ញុំបានឲ្យបងប្អូននិងហើយគេយកកូននិងទៅឲ្យគេមួយទៀតទៅ។

កៈ បាទ! អញ្ចឹងអ៊ុំឲ្យបងប្អូនអ៊ុំហើយ
។ហើយបងប្អូនរបស់អ៊ុំយកកូននិងទៅឲ្យគេមួយបន្តទៀតទៅ។

ខៈ ចាំ! ហើយយើងទៅរកវិញគាត់ឲ្យគេបាត់ហើយនិង។

កៈ បាទ! អញ្ចឹងបើគិតមកដល់ឥឡូវនិងប្រហែលជាគាត់ធំបាត់ទៅហើយនុសអ៊ុំស្រី?

ខៈ ចាំ! ប្រហែលធំហើយព្រោះអីគេបានទៅនៅជាមួយគេអ្នកមាន។

កៈ
អញ្ចឹងអ៊ុំបើនិយាយមកពេលដែរអ៊ុំបានរៀបការជាមួយស្វាមីរបស់អ៊ុំតើមានបានដែរស្គាល់គ្នាពីមុនមកឬក៏ធ្លាប់ណាត់ជួបគ្នាពីមុនមកទេអ៊ុំស្រី?

ខ៖ ខ្ញុំជួបគ្នានៅផ្ទះនិងហើយស្រលាញ់គ្នានៅផ្ទះនិងគ្មានទៅណាទេ។

ក៖ អញ្ចឹងអ៊ុំពេលគាត់ចូលស្ដីដណ្ដឹងអ៊ុំនិងតើគាត់ឲ្យជំនូនអ៊ុំប៉ុន្មានដែរអ៊ុំស្រី?

ខ៖ កាលជំនាន់តិចតួចនិង។

ក៖ បាទ! អញ្ចឹងអ៊ុំប្រហែលប៉ុន្មានដែរអ៊ុំស្រី?

ខ៖ គ្មានបានប៉ុន្មានទេអត់ទាំងអស់គ្នានិងគ្មានបានប៉ុន្មានទេ។

ក៖ ប្រហែលជាប៉ុន្មានដែរអ៊ុំឬក៏សែនទាំងអស់គ្នាទៅអញ្ចឹងមែនអ៊ុំ?

ខ៖ ចាំ! គ្មានបានប៉ុន្មានទេបានត្រឹមសែនទៅនិង។

ក៖ បាទ! បានត្រឹមសែនទេអ៊ុំស្រី។

ខ៖ ចាំ! បានត្រឹមសែននិង។

ក៖ បានត្រឹមសែនឲ្យគេបានដឹងលឺទៅ។

ខ៖ ចាំ!
បានត្រឹមឲ្យគេបានដឹងលឺនិងគាត់គ្មានលុយណាធ្វើទាហាននិងខាងនេះក៏អត់ខាងនោះក៏អត់ដែរនិង។

ក៖ ហើយអញ្ចឹងសូមទោសអ៊ុំមានចេះអានឬសរសេរអក្សរបានច្បាស់ទេ។

ខ៖ អត់បានចេះទេហើយអត់ចេះទាំងអស់គ្នានិងតែបានចៅចេះ។

ក៖ បាទ!

ខ៖ ហើយខ្ញុំឲ្យវាទៅរៀនរាល់ថ្ងៃនិងវាបានរៀនត្រឹមថ្នាក់ទីប្រាំ។

ក៖ បាទ! អញ្ចឹងអ៊ុំកាលនៅពីក្មេងបានចូលរៀនអត់អ៊ុំ?

ខ៖ ខ្ញុំនិង។

ក៖ បាទ!

ខ៖ ចូលរៀនមិចបើអត់យ៉ាងនេះនោះ។

ក៖ បាទ!

ខ៖ បានចូលរៀនអីព្រោះខ្ញុំចិញ្ចឹមម្ដាយចាស់និងណាស់។

ក៖ បាទ!

ខ៖
ម្ដាយចាស់ជរាហើយចាក់នំគ្រួបហើយឆ្លាតទៅបះស្លឹកលក់ហើយស្មានេះអត់ទាន់មកទេបះទាល់ដល់ម៉ោង
១:30នាទីបានមកដល់ហើយពេលបានមកអត់មានបានបាយហូបទៀត។ហើយបើខ្ញុំនិយាយពីប្រវត្តិខ្ញុំវាជូរចិតណាស់។

ក៖ បាទ! អញ្ចឹងជីវិតរបស់អ៊ុំមានការជូរចិតច្រើនអ៊ុំស្រី។

ខ៖ បើនិយាយអំពីជីវិតខ្ញុំមានការឈឺចាប់ណាស់ខ្ញុំមិនចង់និយាយទេ។

ក៖ បាទ!ចឹងភាសាបរទេសវិញអ៊ុំតើអ៊ុំមានចេះអីខ្លះៗទេអ៊ុំដូចជាភាសាថៃ
វៀតណាមអីណាស់អ៊ុំ?

ខ៖ អត់ទេអត់មានទេ។

ក៖ បាទ!ចឹងតើស្វាមីរបស់អ៊ុំវិញតើគាត់ចេះភាសាខ្មែរទេ?

ខ៖ គាត់ខ្មែរគាត់ចេះអក្សខ្មែរតា។

ក៖ បាទ!គាត់ចេះសរសេរចេះអានអក្សរខ្មែរដែលអ៊ុំ?

ខ៖ ចាំ!

ក៖បាទ!ចឹងបើរភាសាបរទេសវិញតើអ៊ុំមានបានឃើញគាត់ធ្លាប់និយាយទេអ៊ុំ?

ខ៖ អត់ទេ។

ក៖ បាទ!ចឹងគាត់អត់ដែលធ្លាប់និយាយទេអ៊ុំ?

ខ៖ ចាំ!ខ្ញុំអត់ដែលលឃើញទេតាគាត់ធ្លាប់រៀនគេចេះហើយខ្ញុំមិនចេះទេ។

ក៖ បាទ!ចឹងតើអ៊ុំបានធ្វើអ្វីខ្លះនៅក្នុងជីវិត្តរបស់អ៊ុំណាស់អ៊ុំ?

ខ៖ ខ្ញុំមានតាលាងចានអោយគេនឹងមានតាពិននឹងមានអីទៀតទេ។

ក៖ បាទ!ចឹងនៅពេលនៅក្នុងផ្ទះវិញអ៊ុំជាមេផ្ទះទៅ?

ខ៖ ចាំ!យើងមើលថៅមើលអីទៅងូតទឹកអោយថៅអីទៅ។

ក៖
បាទ!ចឹងអ៊ុំកាលនៅពីក្មេងណាអ៊ុំតើអ៊ុំមានបានធ្លាប់ទៅស៊ីឈ្នួរគេដូចជាដក់ស្ទុងធ្វើស្រែចំការអីណាស់អ៊ុំ?

ខ៖ ខ្ញុំធ្លាប់តាការខ្ញុំនៅស្រែ។

ក៖ បាទ!តើអីគេខ្លះដែរអ៊ុំ?

ខ៖ ខ្ញុំចេះដកស្ទុងធ្វើស្រែដកសំណាបអីនឹង។

ក៖ បាទ!ដកស្ទុងដកសំណាបអីនឹងទៅបាទខែប្រាំខែវស្សារអីទៅ?

ខ៖ ចាំ!ចិញ្ចឹមកូន។

ក៖ បាទ!នៅពេលនឹងបានប៉ុន្មានដែលអ៊ុំ?

ខ៖ នៅពេលនឹងបានតាប៉ុន្មានពាន់នឹង១៥រយនឹង។

ក៖ បាទ!នៅពេលនឹងបានតា១៥រយតែការជំនាន់នឹងច្រើនណាស់អ៊ុំ?

ខ៖ បាន១៥រយជំនាន់នឹងច្រើនណាបានតាមួយកាក់ៗនឹង។

ក៖ បាទ!បានតាមួយកាក់ៗ?

ខ៖ ចាំ!នឹងហើយបានមួយកាក់មួយពាន់ហូបបានបាយតាមួយពេលនឹង។

ក៖ បាទ!ចឹងអ៊ុំតើអ៊ុំដក់បានប៉ុន្មានផ្លូនដែលអ៊ុំ?

ខ៖ បានតាពីរផ្លូតបីផ្លូននឹង។

ក៖ អរបាទ!អ៊ុំធ្វើបានពីរបីផ្លូតដែលបានបីបួនពាន់ដែលនឹង?

ខ៖
ចាំ!បានបួនពាន់បានអោយថៅបើលកូនទៅទៀតទៅបានគ្រាន់បើតែបើកូនខ្ចីក៏អត់ទៅ។

ក៖ បាទ!ចឹងនៅពេលអ៊ុំស៊ីឈ្នួលដក់ស្ទុងអោយគេនឹងអ៊ុំមានកូនហើយមានប្ដីអស់ហើយ?

ខ៖
ចា៎!ពេលនឹងខ្ញុំមានប្ដីហើយប្ដីខ្ញុំពេលនឹងវៀតតានៀលទៀតប្ដីគេមកបើលឡាននេះទៅដឹងថាប្ដីនឹងគេមានអីខ្លះ។

ក៖
បាទ!ចឹងអ៊ុំនៅពេលនីភូមិណាស់តើអ៊ុំមានមិនភក្តិជិតស្និតដែលដើរលេងជាមួយអ៊ុំណាស់?

ខ៖ អត់មានទេ។

ក៖ បាទ!អ៊ុំអត់មានទេ?

ខ៖ ចា៎!ខ្ញុំអត់ដែលមានផងនឹងអត់ម៉ង។

ក៖ បាទ!ចឹងហើយជីវិត្តរបស់អ៊ុំតាំងពីតូចមកណាស់អ៊ុំតើអ៊ុំមានអ្វីដែលផ្លាស់ប្ដូរទេអ៊ុំ?

ខ៖ កាលពីខ្ញុំនៅក្មេងខ្ញុំដើរបេះឈូកបេះអីណាស់។

ក៖ បាទ!

ខ៖
នៅពេលខ្ញុំមានប្ដីខ្ញុំផ្លាស់ប្ដូរនៅពេលប្ដីខ្ញុំចិញ្ចឹមខ្ញុំតិចណាស់ដល់ពេលប្ដីខ្ញុំមានស្រីទៅបាត់ទៅខ្ញុំជីវិត្តខ្ញុំមួយសារទៀតហើយមកទៀតហើយ។

ក៖ បាទ!

ខ៖
កាលពីក្មេងក៏ពិបាកហើយមកដល់មានប្ដីខ្ញុំមិនសូវពិបាកទេដល់ខ្ញុំមានចៅមានកូនខ្ញុំពិបាមួយសារតៀតហើយពិបាកក្នុងជីវិត្តមួយសារទៀតហើយ។

ក៖ បាទ!ចឹងអ៊ុំមិនអ៊ុំប្រាប់ខ្ញុំថាប្ដីអ៊ុំជាអ្នកបើលឡានអោយគេឬមួយក៏បើកឡានខ្លួនឯងអ៊ុំ?

ខ៖ គាត់បើកឡានអោយគេនឹង។

ក៖
អរគាត់ជាអ្នកបើកឡានអោយគេទេចឹងនៅពេលអ៊ុំមានប្ដីទៅអ៊ុំប្រុសគាត់អោយលុយមកខ្លះទៅអ៊ុំរកលុយខ្លះទៅ?

ខ៖
នៅរក់ស៊ីជាមួយគ្នាចឹងណាស់នៅយូរៗទៅណាស់ដល់គេទៅបើកឡានទៅគេទៅមានស្រីមានញីចឹងទៅណាស់។

ក៖ អរបាទ!ដល់ពេលគេទៅបាត់ចឹងទៅគេមកវិញទៅ?

ខ៖ អត់ទេគេបាត់ម៉ង។

ក៖ អរចឹងគាត់ទៅរហូតម៉ងអ៊ុំ?

ខ៖
នឹងហើយទៅរហូតដល់សព្វថ្ងៃនឹងទៅដល់ខ្ញុំចិញ្ចឹមចៅដល់សព្វថ្ងៃនឹងនោះស្រលាញ់ចៅចង់ងាប់ក៏គេមិនមកផងដល់រាលថ្ងៃនឹង។

ក៖ បាទ!ចឹងអ៊ុំចំពោះមិខម្ហូបវិញណាស់អ៊ុំតើអ៊ុំចូលចិត្តម្ហូបមួយណាដែលអ៊ុំដូចជា សម្លម្ចូ កកូរ សម្លក់ ។ល។ចឹងណាស់អ៊ុំ?

ខ៖ ខ្ញុំចូលចិត្តតាប្រហុកអីទេ។

ក៖ បាទ!ប្រហុកចិញ្ចាមអីនឹងអ៊ុំ?

ខ៖
ប្រហុកអីក៏បានដែលអោយតាហូបបានដល់ពេលចៅចង់ចានពងទាចានអោយចៅទៅមានទាំងអស់។

ក៖ បាទ!តាំងពីក្មេងមកណាស់អ៊ុំ?

ខ៖ ចា៎!ម្តាយខ្ញុំគាត់ធ្វើអីខ្ញុំហូបតានឹង។

ក៖ បាទ!ដល់ពេលម្តាយអ៊ុំធ្វើអីអ៊ុំហូបនឹងទៅ?

ខ៖ ដល់ពេលយើងចាស់ទៅយើងអីក៏ហូបដែល។

ក៖
បាទ!ចឹងអ៊ុំតើអ៊ុំកាលនៅពីក្មេងតើអ៊ុំចូលចិត្តរាំទេអ៊ុំដូចជាមានកម្មវិធីបុណ្យទានអីចឹងណាស់អ៊ុំ?

ខ៖
អត់ទេកាលពីក្មេងខ្ញុំរាំមែនខ្ញុំនៅក្នុងសាលាដែកនេះដូចថាគេស្នើណាស់ដល់ពួកនាក់នេះ

គេស្នើទៅគេមកស្នើហើយគេមកស្នើដល់ម្តាយអីនឹងណាស់គេអោយទៅក៏ទៅជិះឡានអីទៅណាស់ពិននឹងដល់ពេលរាំរួតទៅគេយកមកវិញមក។

ក៖ បាទ!រាំលក់ផ្កាអីចឹងទៅ?

ខ៖ អត់ទេគេស្នើដូចថាគេមានប្រធាននារីចឹងណាស់។

ក៖ បាទ!

ខ៖ គេដើរ។

ក៖ គេដើរតាមភូមិដល់ពេគេមានកម្មវិធីក្នុងវត្តអីចឹងណាស់?

ខ៖ នឹងហើយគេអោយទៅៗដូថាគេអោយស្នើម្តាយអត់អោយទៅគឺអត់អោយទៅហើយ។

ក៖ អរបាទ!គេមកស្នើពីម្តាយសិនដែលអ៊ុំណាស់?

ខ៖ ចាំ!នឹងហើយ។

ក៖ បាទ!ចឹងអ៊ុំបើលល្បែងប្រជាប្រិយវិញតើអ៊ុំចូលចិត្តមួយណាដែលដូចជាបោះឈូង ទាញព្រាត បោះអង្គុន លាក់កន្សែង។ល។អីចឹងណាស់អ៊ុំតើអ៊ុំចូលចិត្តមួយណាដែលអ៊ុំ?

ខ៖ អត់សោះ។

ក៖ បាទ!ចឹងអ៊ុំអត់ដែលលេងម៉ងអ៊ុំ?

ខ៖ អត់ម៉ងអត់ដែលលេងផង។

ក៖ បាទ!ចឹងអ៊ុំបានតារាំទេ?

ខ៖ ខ្ញុំបានតារាំតិចបើលមិនបានខ្ញុំមិនទៅផង។

ក៖
បាទ!ចឹងអ៊ុំមានចូលចិត្តចម្រៀងទេដូចជាច្រៀងបទពីដើមអីណាស់អ៊ុំសម័យអីនឹងអ៊ុំដូចអ្នកស្រីហឹមសីវ៉ន?

ខ៖ គ្មានទេច្រៀងក៏មិនចេះអីក៏មិនចេះដែលរាំក៏ខ្ញុំមិនសូវចេះរាំដែលឥឡូវនឹងនោះ។

ក៖ បាទ!តែនៅភ្នំពេញអ៊ុំចេះរាំណាស់អ៊ុំ?

ខ៖ ដល់ពេលខ្ញុំពិបាកចិត្តពេកទៅខ្ញុំទៅណារូត។

កៈ បាទ!អ៊ុំសប្បាយចិត្តពេក?

ខៈ
ចា៎!ខ្ញុំសប្បាយចិត្តពេកពាលថ្ងៃនឹងគ្មានអីទេនៅផញទៈនឹងរាល់ថ្ងៃនឹងដីគេតាខ្ញុំសុំគេអោយតាចៅបានរស់នៅទៅដល់វាធំទៅអាងយើងទៅទៀត។

កៈ បាទ!អោយតាចៅអ៊ុំបានរៀនអោយមានអនាគត?

ខៈ
ចា៎!អោយតាវារៀនទៅអស់ទៅបានគេជួយអីទិតទូតទៅគុំអីខ្ញុំងាប់រក់ណាបានខ្ញុំបានមួយថ្ងៃបានតាមួយម៉ឺននឹងខ្ញុំរកអីហូបអី។

កៈ
បាទ!ចឹងអ៊ុំតើនៅក្នុងគ្រួសាររបស់អ៊ុំណាស់តើបងស្រីបងប្រុសតើពួកគាត់មានចេះលេងឧបគន៍តន្រីដូចជា ស្គរ ឃឹតា ខ្វាលឈ្វាអីចឹងណាស់អ៊ុំតើពួកគាត់មានចេះទេអ៊ុំ?

ខៈ អត់មានពីណាគេចេះសោះអត់អាលីងម៉ង។

កៈ បាទ!ចឹងឧបគន៍ខ្មែរក៏អត់ចេះដែល?

ខៈ អត់អាលីងម៉ង។

កៈ អរបាទ!អត់អាលីងម៉ង?

ខៈ មានតាដើរធ្វើខ្ញុំគេនឹង។

កៈ
បាទ!កូនចៅជំនាន់ក្រោយគាត់បានធូរហើយដល់ពេលគាត់បានរៀនសូត្រចេះដឹងទៅគាត់មានការងារល្អធ្វើគាត់ចិញ្ចឹមអ៊ុំវិញហើយបាទចឹងអ៊ុំតើផ្ទះរបស់អ៊ុំតាំងពីអ៊ុំនៅពីក្មេងមកណាស់តើមានលក្ខណះអ្វីខ្លះដែលអ៊ុំដូចជាផ្ទះក្បឿងឬមួយផ្ទះទៀមអីរចឹងណាស់អ៊ុំ?

ខៈ ផ្ទះខ្ញុំមុនផ្ទះស្លឹកនឹង។

កៈ អរបាទ!ចុះដំបូលវិញអ៊ុំតើដំបូលអីគេដែលអ៊ុំ?

ខៈ ដំបូលស្លឹកនឹង។

កៈ បាទ!ដំបូលស្លឹកនឹងតើស្លឹកអីគេដែលអ៊ុំ?

ខៈ ស្លឹកត្នោតយើងនឹង។

កៈ អរបាទ!ស្លឹកត្នោតហើយជញ្ជាំងស្លឹកត្នោតដែលទៅ?

ខៈ ចាំ!ស្លឹកត្នោតទាំងអស់។

កៈ បាទ!ចឹងចុះអានៀបអ៊ុំ?

ខៈ អានៀបអាសីអាសីយើងនឹង។

កៈ បាទ!ចេះតានៅទៅអោយតាបានជុំឪពុកម្តាយ?

ខៈ ជុំអីមានតាម្តាយផង។

កៈ បាទ!ចឹងអ៊ុំតើផ្ទះនឹងតើប៉ារបស់អ៊ុំធ្វើដោយផ្ទាល់ឬមួយប៉ារបស់អ៊ុំជួរគេធ្វើដែលអ៊ុំ?

ខៈ អត់ទេផ្ទះនឹងរបស់ម្តាយខ្ញុំម៉ង។

កៈ អរចឹងផ្ទះនឹងរបស់ម្តាយរបស់អ៊ុំតាំងពីយូរមកហើយ?

ខៈ មានដូចថាមានបើផ្ទះស្លឹកចឹង។

កៈ បាទ!កាលពីសង្គមផ្ទះស្លឹកគឺល្អណាស់?

ខៈ
ផ្ទះស្លឹកដូចផ្ទះចឹងដែលនឹងមានផ្ទះធំអីផ្ទះចឹងដែលនឹងបានវាមិនបានដូចជាមានស្លឹករយេរយ៉ាយ។

កៈ
បាទ!ចឹងអ៊ុំមានចាំថាកាលគាត់ធ្វើផ្ទះនឹងតើមានឧបគន៍អ្វីខ្លះដែលអ៊ុំសំរាប់ធ្វើផ្ទះនឹងដែលអ៊ុំ?

ខៈ អត់អាលីង។

កៈ បាទ!ចឹងអ៊ុំអត់ដឹងទេ?

ខៈ អត់មានម៉ង។

កៈ បាទ!

ខៈ
មានតាអង្គរហើយនឹងម្ជូបនឹងអំបិលប្រហុកនឹងអត់មានទាំងអស់មានតាភ្លើងមួយគេកាលនឹងដាក់រដ្ឋទៀតណាស់រដ្ឋគេដាក់អោយ។

កះ បាទ!រដ្ឋគេដាក់អោយទៀត?

ខះ ចា៎!រដ្ឋគេអោយ។

កះ បាទ!ចឹងខំអីត្រូវអត់មានភ្លើងទៀត?

ខះ ចា៎!ខំអីអត់ទៀត។

កះ
បាទ!ចឹងរាលថ្ងៃនឹងយើងបានគុណបុណ្យរាជរដ្ឋាភិបាលគេដោះស្រាយអោយជនក្រីក្រខ្លះបាទបើលសិនអត់ជួយសោះក៏បិបាកហើយអ៊ុំមិនដឹងទៅណាមកណាទេបាទចឹងអ៊ុំតើលោកឪពុកម្ដាយរបស់អ៊ុំតើពួកគាត់មានចេះជំនាន់អ្វីខ្លះទេអ៊ុំដូចជាត្បាញ អីចឹងណាស់អ៊ុំ?

ខះ អត់ទេ។

កះ ត្បាញកន្ទេល កូរស្ករត្នោតអីចឹងណាស់អ៊ុំ?

ខះ អត់ទេអត់មានទាំងអស់។

កះ បាទ!ចឹងអ៊ុំអត់មានអីដែលចេះពីគាត់ទេ?

ខះ ចា៎!អត់មានទេ។

កះ បាទ!ចឹងតើគាត់ចេះទេអ៊ុំ?

ខះ ខ្ញុំមិនដឹងថាគាត់ចេះក៏អត់ទេ។

កះ បាទ!អ៊ុំអត់ដឹងដែលណាសអ៊ុំ?

ខះ ចា៎!យើងនៅតូចដែលពេលនឹងដល់ពេលខ្ញុំធំទៅគាត់មិនដែលនិយាយប្រាប់ខ្ញុំផងនឹង។

កះ បាទ!តែតាំងពីដឹងក្ដីមកគាត់រៀតតានៀលរហូត?

ខះ ចា៎!រៀតតានៀលរហូតនឹង។

កះ
បាទ!ចឹងអ៊ុំតាំងពីតូចរហូតមកដល់ធំតើអ៊ុំបានឆ្លងកាត់នៅរៀតតានៀលអ្វីខ្លះដែលថាលំបាកខ្លាំងណាស់អ៊ុំនៅក្នុងជីវិត្តរបស់អ៊ុំដែលអ៊ុំ?

ខះ នេះគ្រាដែលខ្ញុំពិបាកហើយ។

កៈ បាទ!ពិបាកមិចដែលអ៊ុំ?

ខៈ
ពិបាកណាស់ពិបាកអ្វីខ្លះចាំមើលខ្ញុំនិយាយពិបាកការរស់នៅចិញ្ចឹមក៏ពិបាកនិយាយជាមួយថៅក៏ពិបាកហើយខ្ញុំពិបាកចិត្តណាស់។

កៈ បាទ!ចឹងនិយាយជាមួយថៅពិបាកមិចដែលអ៊ុំនិយាយទៅគាត់អត់ស្តាប់មែនអ៊ុំ?

ខៈ យើងនិយាយទៅគេអត់ស្តាប់យើងគេចឹងណាស់។

កៈ បាទ!

ខៈ ដូចថាយើងអង្គុយៗចឹងទៅយើងថាយើងនៅដីគេវាមិនស្រួលណា។

កៈ បាទ!យើងនិយាយចឹងយើងចង់ដាស់ទើនគាត់អោយគាត់ខំប្រឹង?

ខៈ
ចាំ!នឹងហើយកាលជំនាន់ខ្ញុំដេកក្រោមផ្ទះគេវៀតតានៀលណាស់គេថាក់ខ្ញុំចូលទឹកចូលភុកណាស់។

កៈ បាទ!

ខៈ
ក៏មានដែលហើយខ្ញុំវៀតតានៀលណាស់ដល់ពេលអ្នកជិតខាងគេនិយាយប្រាប់ខ្ញុំថាយកកូនមកនៅនេះមកហើយផ្ទះនឹងខ្ញុំធ្វើខ្លួនឯងនឹង។

កៈ អរបាទ!ចឹងផ្ទះនឹងអ៊ុំធ្វើដោយខ្លួនឯង?

ខៈ ចាំ!ខ្ញុំធ្វើខ្លួនឯងទេគ្មានពីណាគេជួយខ្ញុំទេខ្ញុំវៃធ្វើខ្លួនឯងនឹង។

កៈ បាទ!ចឹងជំបូលដាក់អីគេដែលអ៊ុំសង័សីទៅអ៊ុំ?

ខៈ សង័សីនឹងរហែកទៀតណាស់បានប្រធានក្រុមគេយក។

កៈ បាទ!គេយកបារទង់មកអោយ?

ខៈ
ចាំ!នឹងហើយបានប្រធានក្រុមគាត់ចិត្តបានណាស់មិនដូចប្រធានក្រុមផ្សេងទេគាត់ចិត្តបានណាស់អោយតែគេហៅទៅចែកអំណាយអីគឺគាត់ហៅទៅហើយ។

ក៖ បាទ!ចឹងអ៊ុំធ្វើផ្ទះខ្លួនឯងនឹងអស់រយះពេលប៉ុន្មានខែដែលបានហើយអ៊ុំ?

ខ៖ គៀនៗនេះរបស់គេយើងធ្វើបានតាកណ្តាលនឹង។

ក៖
អរយើងអាងថាគៀនៗនេះរបស់គេយើងបានខាងគេទៅយើងបានទប់ៗទៅបាទ!ចឹងអ៊ុំមានសំភារះអ្វីខ្លះបានជាអ៊ុំធ្វើបានអ៊ុំមានដូចជាឈើអី?

ខ៖ ឈើនឹងគេអោយ។

ក៖ ឈើគេអោយទៀត?

ខ៖ ចាំ!គេអោយសង័សីគេអោយទៀតគេអោយទាំងអស់នឹង។

ក៖ បាទ!គេអោយទាំងអស់?

ខ៖ ចាំ!គេឃើញយើងក្រ។

ក៖ បាទ!ចឹងអ៊ុំមានតាកម្លាំងធ្វើទេ?

ខ៖ ចាំ!កាលមុនខ្ញុំដេកនៅនោះខ្ទមតូចទេ។

ក៖ បាទ!

ខ៖
គេឃើញយើងចឹងគេចេះតែហុតឈើហុតអីអោយទៅណាស់ហើយយើងយកមកវៃមកហើយខ្ញុំវៃនៅក្នុងផ្ទះនឹងនៅទៅដល់ហើយក្មួយខ្ញុំនឹងណាស់វាឃើញខ្ញុំពិបាកពេកក៏វាមកជួយធ្វើនឹងទៅ។

ក៖ បាទ!ចឹងអ៊ុំបានក្មួយជួយធ្វើទៀត?

ខ៖ នឹងហើយវាបានជួយធ្វើ។

ក៖ បាទ!ចឹងតើក្មួយប្រុសឬមួយក្មួយស្រីដែលអ៊ុំ?

ខ៖ ក្មួយប្រុសនឹង។

ក៖ អរក្មួយប្រុស?

ខ៖ ក្មួយខ្ញុំវារៀងពិបាកទិចអោយវាវៃអត់ទិញស្រាផឹកអត់បានទៀត។

កៈ
អរ!ទិញស្រាអោយផឹកទៀតបាទចឹងអ៊ុំតើអ៊ុំមានបានឆ្លងកាត់នៅសម័យសង្គ្រាមអាពតទេអ៊ុំ?

ខៈ ខ្ញុំណាស់។

កៈ បាទ!តើអ៊ុំបានឆ្លងកាត់នៅអ៊ុំ?

ខៈ នៅ។

កៈ បាទ!តើអ៊ុំមានបានឆ្លងកាត់នៅសម័សង្គ្រាមអាពតតើអ៊ុំមានកាលលំបាកអ្វីខ្លះដែលអ៊ុំ?

ខៈ
ខ្ញុំមិនសូវពិបាកប៉ុន្មានទេពិបាកតាគេអោយយើងយកអាច់គោយកមកថ្លឹងណាស់យើងបានមួយរយទៅបើលយើងអត់បានមួយរយគេនិទាញយើងណាស់។

កៈ គេនិទាញនឹងគេហៅថាទៅអបរំអីចឹងណាស់?

ខៈ នឹងហើយគេហៅយើងទៅអបរំ។

កៈ បាទ!ចឹងកាលនៅក្នុងសម័យសង្គ្រាមនឹងតើអ៊ុំមានអាយុប៉ុន្មានហើយអ៊ុំ?

ខៈ អាយុប្លែ១០ឆ្នាំនឹង។

កៈ
បាទ!អាយុ១០ឆ្នាំកើបអាច់គោហើយនឹងកាប់កន្តេងខែតទៀតបាទនៅពេលនឹងគេហៅថាសមាមិត្តកុមារ?

ខៈ នឹងហើយពេលនឹងប្រហែអាយុ៨ឆ្នាំអីទេ។

កៈ
បាទ!នៅពេលនឹងអាយុប្រហែល៨ឆ្នាំអីទេបាទកាលនឹងកើបអាច់គោកើបអាចសេះទៅអ៊ុំ?

ខៈ ចាំ!កាលនឹងកើបអាចគោអាចសេះបើមិនបានច្រើទេវារករឿងយើងហើយ។

កៈ
បាទ!ចឹងនៅពេលនឹងគេមានដែលប្រើលអោយអ៊ុំទៅជាន់ទាន់រហាត់ទឹកនៅស្រែអីទេអ៊ុំ?

ខៈ អត់ម៉ែខ្ញុំគាត់ជាចុងភៅ។

កៈ អរបាទ!ម្តាយរបស់អ៊ុំជាចុងភៅ?

ខ៖ ចា៎!ម្តាយរបស់ខ្ញុំគាត់ជាចុងភៅ។

ក៖
បាទ!ចឹងមានន័យថាអ៊ុំមានការហូបចុកខុសពីអ្នកដទៃព្រោះគាត់អាចលាក់លួតអីបន្តិបន្តួតអី?

ខ៖ បានជំនាន់នឹងគាត់លាក់ពីគេមកហើយយកលាក់អោយបងចិញ្ចឹមទៀតណាស់។

ក៖ បាទ!បងឯងចិញ្ចឹមបងមួយទៀត?

ខ៖ ចា៎!

ក៖ ចឹងកាលនឹងតើអ៊ុំមានបានចាំឈ្មោះគាត់ទេ?

ខ៖ អត់សោះ។

ក៖
បាទ!តែអ៊ុំមានភាពជិតស្និតជាមួយគ្នាបាទចឹងអ៊ុំមានលក្ខណះមានកាលសប្បាយដែលខ្លាំងបំផុតណាស់ដែលនៅក្នុងជីវិត្តរបស់អ៊ុំណាស់តើនៅពេលណាដែលអ៊ុំលក្ខណះថាតាំងពីក្មេងរហូតមកដល់ធំណាស់ដូចថាការសប្បាយបុណ្យទានអីសប្បាយដើរលេងជាមួយបងប្អូនអីណាស់?

ខ៖ អរបុណ្យទានអីខ្ញុំ។អត់សូវម៉ែងខ្ញុំអត់សូវជុំណូលម៉ង។

ក៖ បាទ!ចឹងតើថ្ងៃណាដែលអ៊ុំសប្បាយជាងគេដែលនៅក្នុងគ្រួសារអ៊ុំណាស់?

ខ៖ ដូចថាពេលសប្បាយយើងសប្បាយទាំងអស់គ្នាទាំងម្តាយទាំងកូនណាស់។

ក៖ បាទ!សប្បាយលក្ខណះជាគ្រួសារណាស់អ៊ុំ?

ខ៖ ចា៎!ទៅមើលគុនទៅមើលអីទៅ។

ក៖ អរទៅមើលគុនទៀត?

ខ៖ ទៅមើលគុននៅសាលាដែកនឹងតាមមុនៗខ្ញុំអត់ដែលដើរលេងទេ។

ក៖ បាទ!គុននឹងរឿងគេមែនអ៊ុំ?

ខ៖ អត់ទេកាលពីជំនាន់វៀតណាមណាស់។

ក៖ បាទ!គុនអីគេដែលអ៊ុំ?

ខ៖ ជំនាន់នឹងវៀតណាមគេមិនដាក់អាគុនកណាត់ៗ។

ក៖ អរគុនកណាត់ៗគេដាក់ករណាត់អោយយើងមើលនឹងអ៊ុំ?

ខ៖ កាលនឹងវៀតណាមច្រើន។

ក៖
បាទ!ឥឡូវក៏ច្រើនដែលបាទចឹងនៅពេលបងស្រីគាត់រៀបការចឹងណាស់តើនៅពេលនឹងតើអ៊ុំសប្បាយទេអ៊ុំ?

ខ៖ នៅពេលជិតការកូនខ្ញុំសប្បាយដែលនឹងតែហាត់ក៏វាហាត់ដែល។

ក៖ បាទ!សប្បាយម៉ាងដែលអ៊ុំបានកូនមានស្វាមីចេះដូចថាក្រុមគ្រួសារមានសុភមង្គរ?

ខ៖ ខ្ញុំបានឃើញកូនរៀបការចឹងទៅខ្ញុំមានចិត្តសប្បាយរីករាយដែល។

ក៖
បាទ!ចឹងអ៊ុំនៅពេលកាលអ៊ុំនៅពីក្មេងណាស់រហូតមកដល់ធំណាស់តើអ៊ុំមានពងប្រាថ្នាចង់ធ្វើជាអ្នកគ្រូបង្រៀត គ្រូពេទ្យអីណាស់អ៊ុំ?

ខ៖ អីក៏ខ្ញុំអត់ចង់ដែល។

ក៖ ចឹងអ៊ុំមានគោរបំណាងទេអ៊ុំ?

ខ៖ អត់។

ក៖ អត់មានសោះម៉ងអ៊ុំ?

ខ៖ អត់មានសោះ។

ក៖ បាទ!ចឹងអ៊ុំអត់មានចង់ធ្វើជាទាហានធ្វើអីទេអ៊ុំ?

ខ៖ អត់អាលីង។

ក៖ អរចឹងអ៊ុំចង់ធ្វើអ្វីដែលសាម៉ាន់ៗ?

ខ៖ អត់ក្រអោយវាទៅតាមក្រទៅបើលវាចឹងហើយ។

ក៖
បាទ!ចឹងតើអ៊ុំចង់ផ្តាំទៅកាន់កូនចៅជំនាន់ក្រោយរបស់អ៊ុំណាស់តើអ៊ុំមានអ្វីដែលត្រូវផ្តាំផ្ញើលទេអ៊ុំ?

ខ៖
នឹងហើយខ្ញុំបានប្រាប់ចៅប្រាប់កូនតែឥឡូវគេមានកូនមានអីរស់ហើយខ្ញុំប្រាប់តាចៅទេរាល់ថ្ងៃនឹងនេះ។

ក៖ បាទ!អ៊ុំគ្រាន់តែចង់អោយចៅមានអនាគត?

ខ៖
នឹងហើយខ្ញុំគ្រាន់តែចង់អជយចៅមានអនាគតហើយខ្ញុំនិយាយថាអោយចៅនឹងនេះទៅរៀនអោយចេះកុំអោយដូចយាយខំប្រឹងរៀនសូត្រទៅ។

ក៖ បាទ!ព្រោះយាយធ្លាប់ពិបាកហើយ?

ខ៖
ចាំ!ព្រោះយើងវាធ្លាប់ពិបាកហើយកុំអោយវាដូចយើងអីមើលទៅវៀតតានៀលរាល់ថ្ងៃដើរដេកតាមផ្ទះគេខ្ញុំនិយាយចឹងទៅខ្ញុំចង់អោយវាមានការតស៊ូ។

ក៖
បាទ!ចឹងអ៊ុំបើលខាងជៀសវាងវិញណាស់អ៊ុំតើអ៊ុំចង់អោយក្មេងជំនាន់ក្រោយជៀសវៀងអ្វីដែលអ៊ុំដូចជាជៀសវៀងពីគ្រឿងញៀញ ល្បែងស៊ីសង ជៀសវៀងពីក្មេងទំនើង?

ខ៖
ចាំ!ខ្ញុំប្រាប់ចៅដែលថាកុំអោយបះមិនអោយគិតរឿងអីចឹងទេអោយគិតថាហើយពីរឿងរៀននឹងហើយអោយវាចេះគោរពចាស់ទុំដូចថាវាដើរលេងជាមួយពួកម៉ាក់បងតូចបងធំអីខ្ញុំមិនចង់អោយវាដើរជាមួយទេខ្ញុំអោយវាដើរតែឯងនឹងម៉ងអត់ចូលចិត្តទេឥឡូវ។

ក៖ បាទ!អត់ចូលចិត្តទេអ៊ុំណាស់?

ខ៖
ចាំ!ខ្ញុំអត់ចូលចិត្តទេខ្ញុំឃើញនឹងវាច្រើនណាស់មកហើយនេះកូនខ្ញុំមួយនេះវាពិបាកមួយណាស់មកហើយកូននឹងវាជក់គ្រឿងញៀញមួយទៅហើយ។

ក៖ បាទ!កូនអ៊ុំមួយគាត់បានជក់គ្រឿងញៀញណាស់អ៊ុំណាស់?

ខ៖
នឹងហើយខ្ញុំនិយាយអោយស្មោះខ្ញុំអត់មានលក្ខះទេអ្នកជក់គ្រឿងញៀញមានច្រើនណាស់។

ក៖ បាទ!ឪពុកម្តាយមិនដែលចង់អោយកូនខ្លាចទៅជាចឹងទេ?

ខ៖ នឹងហើយម៉ែឪមិនដែលចង់អោយកូនចឹងទេ។

ក៖ បាទ!ម៉ែឪចង់អោយកូនល្អ?

ខ៖
នឹងមកពីយើងទៅដើរលេងជាមួយមនុស្សអាក្រក់បើយើងមិនដើរជាមួយមនុស្សអាក្រក់ក៏យើងមិនចឹងដែលយើងនិយាយអោយដាក់ថាកូនកុំដើរជាមួយអ្នកអាក្រក់បើលយើងដើរជាមួយអ្នកអាក្រក់ហើយវាមិនស្រួលទេ។

ក៖ បាទ!ដើរមិនស្រួលទេ?

ខ៖ មិនស្រួលទេគេចាប់យើងដាក់គុកទៀត។

ក៖
បាទ!ដូចចាស់គាត់និយាយថាដើរជាមួយមនុស្សល្អយើងល្អដើរជាមួយមនុស្សអាក្រក់គឺយើងអាក្រក់ហើយបើយើងដើរជាមួយអ្នករៀនគឺយើងរៀនហើយតែនេះជាពាក្យមួយដែលយើងណែនាំគេទេគឺអ្នកដែលសំរាច់នោះគឺខ្លួនយើងទេបាទ?

ខ៖
បើចឹងខ្ញុំសប្បាយចិត្តណាស់រាល់ថ្ងៃនេះខ្ញុំបានចៅខ្ញុំទៅរៀនខ្ញុំសប្បាយចិត្តណាស់តែបើខ្ញុំឃើញវាដើរលេងជាមួយក្មេងខូតអីហើយមកដល់ផ្ទះរបួសដៃជើងអីដឹងថាខ្ញុំវៃថែមហើយបើលវារបួសលេងមានអីបើទៅវៃគ្នារបួសអីនឹងខ្ញុំវៃថែមម៉ង។

ក៖ បាទ!ដោយសារយើងចង់អោយគាត់ល្អពីក្មេងទៅ?

ខ៖
នឹងហើយព្រោះខ្ញុំនឹងវាស្មាមទៅហើយបើមិនខ្ញុំមិនស្មាមខ្ញុំអត់អីទេព្រោះខ្ញុំប្រដៅគេមួយហើយគេថាអោយយើងវិញចាំខ្ញុំមានតាបិននឹងទេ។

ក៖ បាទ!តើចៅថាអោយវិញឬមួយកូនអ៊ុំដែលអ៊ុំ?

ខ៖ កូនខ្ញុំ។

ក៖ កូនប្រុសមែនអ៊ុំ?

ខ៖ ចាំ!កូនប្រុសតែឥឡូវគេកែប្រែហើយឥឡូវនឹង។

ក៖ បាទ!ឥឡូវគាត់បានកែប្រែហើយអ៊ុំណាស់?

ខ៖ នឹងហើយ។

ក៖ បាទ!ឥឡូវគាត់លែងហើយអ៊ុំ?

ខ៖ នឹងហើយឥឡូវវាលែងហើយ។

ក៖ បាទ!ពីមុនមកគាត់គាត់ខ្លាំង?

ខ៖ នឹងហើយពីមុនមកវាចូលសេពគប់អាគ្រឿងញៀញនឹងមកវាសំលុតយើងយកលុយយើង យើងមានលុយមកពីណាយើងរកមានបានអីយើងមានមួយម៉ឺយើងយកអោយវាមិចយើង មានអីស៊ីបើលយើងអោយទៅខាងនេះខាងនោះអត់ហើយគ្នាមានអីទៅរៀន។

ក៖ បាទ!ចឹងអ៊ុំចោលនេះទៅអោយគ្នាទៅរៀនវិញ?

ខ៖ ចាំ!នឹងហើយសុខចិត្តអោយគ្នាទៅរៀនខ្ញុំសុខចិត្តអោយវាវៃយើង។

ក៖ បាទ!អរចឹងគាត់រកវៃអ៊ុំទៀត?

ខ៖ អីវារកវៃខ្ញុំម្តងដែលណាខ្ញុំយំខ្ញុំសុខចិត្តទុកខ្លួនឯងណាស់ហើយខ្ញុំខ្ទីលខ្ញុំអោយវាមួយម៉ឺនពីរ ម៉ឺនទៅអត់ហៀនទេខ្ញុំមានអោយប្រាំពាន់ទៅដល់ហើយខ្ញុំនិយាយថាឥឡូវម៉ែមានតាមួយម៉ឺ នទេអោយកូនឯងប្រាំពាន់ទុកអោយម៉ែប្រាំពាន់។

ក៖ បាទ!ចឹងតើគាត់យកទេអ៊ុំ?

ខ៖ យកតា។

ក៖ អរយកទៀត?

ខ៖ អរកាលនឹងខ្ញុំផឹកស្រាហើយខ្ញុំនឹពាងយកលុយនឹងដាក់ក្នុងនេះដល់ខ្ញុំដេកលក់មួយរឹងវាក៏ លួតយកលុយខ្ញុំទៅលុយខ្ញុំ៨ម៉ឺអស់អាលីងនឹងខ្ញុំនិយាយស្មោះត្រង់ដល់វាលួតទៅខ្ញុំនឹកឃើ ញថាអត់លុយអោយក្មួយវាទៅរៀនសូត្រណាស់ហើយក៏យកលុយមកដាក់លើតុកទៅ។

ក៖ បាទ!គាត់យកដាក់អោយវិញទៅ?

ខ៖ នឹងហើយយកដាក់អោយវិញទៅ។

ក៖ បាទ!ចឹងនៅពេលនឹងគាត់យកដាក់អោយអ៊ុំវិញប៉ុន្មានដែលអ៊ុំ?

ខ៖ ៨ម៉ឺនវាយក៤ម៉ឺនទៅបាត់ហើយ។

ក៖ អរចឹងគាត់ទុកអោយអ៊ុំវិញ៤ម៉ឺនបានគាត់ចេះគិតគូរដល់ក្មួយគាត់ដែល?

ខ៖
នឹងហើយដល់ក្មួយវាងើបមកវាថាយាយៗលុយយាយអែងនៅលើតុកយាយហើយដល់ពេលនឹងខ្ញុំថាវាយកលុយខ្ញុំ៤ម៉ឺនបាត់ហើយមិនស្រួលនោះដល់ពេលនឹងខ្ញុំងើបមកវាស្វាងស្រវឹងណាស់ខ្ញុំខឹង។

ក៖ បាទ!នឹងហើយកូនផងប្ដីផងណាស់?

ខ៖
កូនណាស់វាឃើញយើងនៅក្រោមផ្ទះគេណាស់វានឹងឃើញហៅយើងណាស់កូនប្រសារអីចឹងណាស់អត់ហៅយើងទេ។

ក៖ អត់ហៅអ៊ុំអត់រាប់អានអ៊ុំសោះម៉ង?

ខ៖ អត់ដល់រាល់ថ្ងៃនឹងមិនស្រួរអីទេ។

ក៖ បាទ!ដល់ពេលអ៊ុំមានផ្ទះអីត្រឹមត្រូវទៅមិនស្រួរអីទេ?

ខ៖ នឹងហើយមិនស្រួរអីទេហៅយើងរហូត។

ក៖ បាទ!ចឹងបើកូនបង្កើតរបស់អ៊ុំនិយាយជាមួយអ៊ុំតាអ៊ុំ?

ខ៖ និយាយតា។

ក៖ អរនិយាយធម្មតាទេ?

ខ៖ កូនខ្ញុំកូនប្រុសនឹងបើកូនស្រីមានអី។

ក៖ អរបាទ!ដូចបងប្រុសគាត់មកផ្ទះរហូតណាស់អ៊ុំ?

ខ៖ វានៅណានោះវាមកដែលនឹងដូចថាវាឃើញម៉ែហត់ចឹងវាចេះតែមកជួយទៅ។

ក៖
បាទ!ចឹងអ៊ុំខ្ញុំសូមអរគុណអ៊ុំច្រើនដែលអ៊ុំបានអនុញ្ញាតិអោយខ្ញុំបានធ្វើការសំភាសន៍អំពីជីតកប្រវត្តិរបស់អ៊ុំណាសអ៊ុំបាទចឹងជាចុងក្រោយខ្ញុំសូមជូនពរអ៊ុំអោយមានសុខភាពល្អហើយនឹងសូមអោយអ៊ុំរកស៊ីមានបានចឹងណាស់អ៊ុំ?

ខ៖ ចា៎!

ក៖
បាទចឹងហើយខ្ញុំសូមអោយអ៊ុំជួបតែសេចក្ដីសុខនឹងសូមអោយគ្រួសាររបស់អ៊ុំមានតែសុភមង្គលបាទចឹងខ្ញុំអស់ហើយខ្ញុំក៏សូមជំរាបលាអ៊ុំដែលបាទសូមអរគុណអ៊ុំម្ដងបាទជំរាបលាអ៊ុំ។